# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជា
## ប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន
## និងសង្គ្រោះជនពិការដោយសារមីន ថ្លែងក្នុងពិធីបើក
## កិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីអនុសញ្ញា ស្តីពីការ
## ហាមប្រាមការប្រើប្រាស់ ការផលិត ការរក្សាទុក
## ការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញវា
## ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១១ នៅវិមានសន្តិភាព

*- លោកជំទាវ Helen Clark នាយិកាកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ឯកឧត្តម ហ្គាសមិន ធីឌ្យូ ( H.E. Gazmend Turdiu) ប្រធានកិច្ចប្រជុំលើកទី ១០ ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ*

*- អស់លោក លោកស្រីទាំងអស់ជាទីរាប់អាន !*

ជាបឋម ខ្ញុំសូមតាងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទាំងមូល សូមសំដែងនូវសេចក្តីរីករាយជាអនេក និងសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះវត្តមានរបស់ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាតំណាងនៃរដ្ឋភាគី និងរដ្ឋមិនមែនភាគីអនុសញ្ញា



អូតាវ៉ា តំណាងអង្គការសហប្រជាជាតិ ស្ថាប័ននានា ដែលអញ្ជើញពីគ្រប់ទ្វីបនៃពិភពលោក មកចូលរួមក្នុងកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីអនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការផលិត ការរក្សាទុកការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញវា ។

ពេញមួយសប្តាហ៍ខាងមុខនេះ ទីក្រុងភ្នំពេញនឹងទទួលស្វាគមន៍កិច្ចប្រជុំលើកទី ១១ នេះ ដែលជាកិច្ចប្រជុំដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រនៃការរំសាយសព្វាវុធ ។

កាលពី ២ ឆ្នាំមុន ទីក្រុងកាតាហេណាប្រទេសកូឡុំប៊ីបានទទួលធ្វើជាទីកន្លែងនៃកិច្ចប្រជុំត្រួតពិនិត្យលើកទី ២ នៃការអនុវត្តន៍អនុសញ្ញាអូតាវ៉ា ។ ផ្អែកលើកំណត់សំគាល់អំពីការជឿនលឿន និងជោគជ័យដែលសំរេចបាន ក៏ដូចជាការមើលឃើញអំពីការប្រឈមនានាដែលត្រូវជំនះពុះពារនោះ តំណាងទាំងឡាយនៃរដ្ឋភាគីបានអនុម័តនូវផែនការសកម្មភាពមួយហៅថា ផែនការសកម្មភាពកាតាហេណា ដើម្បីយកមកអនុវត្តន៍សំរាប់បណ្តាឆ្នាំ ២០១០ ដល់ ២០១៤ ។ ដោយគោរពតាមបន្ទាត់ និងស្មារតីនៃអនុសញ្ញាផែនការសកម្មភាពនេះ បានជំរុញឱ្យរដ្ឋភាគីនានាខិតខំសំរេចការងារសំខាន់ៗ ដូចជា ៖

- បន្តកិច្ចប្រឹងប្រែង ដើម្បីសំរេចសកលភាវូបនីយកម្ម នៃអនុសញ្ញាពោលគឺលើកទឹកចិត្ត បញ្ចុះបញ្ចូលប្រទេសថ្មីឱ្យរួមសាមគ្គីក្នុង

ចលនាដើម្បីសំរេចគោលដៅក្នុងការធ្វើឱ្យពិភពលោកទាំងមូលគ្មានមីន

- ជំរុញការកំទេចគ្រាប់មីនក្នុងឃ្លាំងនៅក្នុងប្រទេសជារដ្ឋភាគីឱ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន
- បន្តការបោសសំអាតមីន រំដោះដីដែលរងការគំរាមកំហែងដោយសារមីនឱ្យបានកាន់តែច្រើន ដើម្បីផ្តល់ដីមានសុវត្ថិភាពសំរាប់ការតាំងលំនៅដ្ឋាន ធ្វើកសិកម្ម និងសកម្មភាពធម្មតាដទៃទៀតរបស់សហគមន៍
- យកចិត្តទុកដាក់ជួយដល់ជនរងគ្រោះដោយសារមីន ឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ ជួយសំរួលនីតិសម្បទា និងសមាហរណកម្មរបស់ពួកគេក្នុងផ្នែកសេដ្ឋកិច្ច-សង្គម
- ព្រួតកំលាំងគ្នា ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ ការតាំងចិត្តខាងនយោបាយចែករំលែកបទពិសោធន៍ និងមេរៀនទាំងឡាយ និងខិតខំកៀរគរជំនួយ ដើម្បីសំរេចគោលដៅនៃអនុសញ្ញា ។

របាយការណ៍វឌ្ឍនភាពទីក្រុងភ្នំពេញ ដែលអង្គប្រជុំនឹងអនុម័តនៅចុងសប្តាហ៍ខាងមុខនឹងធ្វើតុល្យការអំពីសមិទ្ធផល ដែលបានសំរេចក្នុងឆ្នាំកន្លងទៅ ។



ខ្ញុំសូមយកឱកាសនេះ ដើម្បីសំដែងនូវគារវៈកិច្ច និងកោតសរសើរដោយស្មោះចំពោះការខិតខំប្រឹងប្រែងរបស់ប្រទេសន័រវេស និងប្រទេសអាល់បានី ក្នុងវេនជាប្រធានរៀងខ្លួនក្នុងឆ្នាំ ២០១០ និង ២០១១ នេះ ដើម្បីសំរបសំរួល តាមដានជំរុញការអនុវត្តន៍ផែនការសកម្មភាពកាតាហេណា ។

*- ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ !*

ថ្ងៃស្អែកនេះកម្ពុជានឹងទទួលវេនជាប្រធាននៃកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា ហើយនឹងដឹកនាំកិច្ចការពាក់ព័ន្ធទាំងឡាយពេញមួយឆ្នាំ ២០១២ ។

សំរាប់ប្រទេសកម្ពុជា វេនជាប្រធាននេះនឹងផ្តល់បន្ទុកទទួលខុសត្រូវ និងកិត្តិយសដ៏ធំមួយ ក៏ប៉ុន្តែសំរាប់ចលនានៃការហាមប្រាមការប្រើប្រាស់អាវុធមួយនេះ គឺជានិមិត្តរូបដ៏មានសារៈសំខាន់បំផុត ។ ប្រការដែលកិច្ចប្រជុំប្រព្រឹត្តទៅនៅក្រុងភ្នំពេញមានន័យថា អនុសញ្ញានេះបានវិលត្រឡប់មកកាន់ទឹកដី នៃការចាប់កំណើតរបស់ខ្លួនកាលពី ២០ ឆ្នាំមុន ។ គឺចេញពីសោកនាដកម្ម ការឈឺចាប់របស់ជនរងគ្រោះដោយសារមីននៅកម្ពុជា ក៏ដូចជានៅតំបន់ស្រដៀងគ្នានៅប្រទេស Mozambique Angola, Afghanistan ឬនៅ Bosnia -Herzegovina នេះហើយដែលការប្តេជាចិត្ត ដើម្បីលុបបំបាត់អាវុធដ៏អមនុស្សធម៌មួយនេះបានកកើតឡើង ។

សោកនាដកម្មកន្លងទៅរបស់ប្រទេសកម្ពុជា គឺជាសោកនាដកម្មដោយឡែកប្រកបដោយការឈឺចាប់បំផុត ។

ប្រវត្តិមីននៅកម្ពុជាត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនឹងប្រវត្តិសាស្ត្រនៃសោកនាដកម្ម ដែលប្រទេសយើងខ្ញុំបានឆ្លងកាត់ក្នុងចន្លោះពីពាក់កណ្ដាលទសវត្ស ៦0 រហូតដល់ចុងទសវត្ស ៩0 ។ នេះជាដំណាក់កាលដ៏ខ្មៅបំផុតមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលត្រូវហែកហួរដោយសង្គ្រាម តំបន់ជម្លោះប្រដាប់អាវុធផ្ទៃក្នុង របបប្រល័យពូជសាសន៍ ការបែងចែកទឹកដី និងការបែកបាក់ក្នុងសង្គមជាតិ ។ ទោះបីស្នូរអាវុធបានរលត់ទៅវិញជាច្រើនឆ្នាំហើយក៏ដោយ ក៏សោកនាដកម្មនេះបានអូសបន្លាយបន្តទៀត ជាមួយនឹងស្នូរផ្ទុះគ្រាប់មីន សំរែកជនរងគ្រោះទុក្ខធំរបស់ក្រុមគ្រួសារ និងសហគមន៍ ។ ក្នុងខណៈដែលប្រជាពលរដ្ឋយើងខ្ញុំត្រូវការស្តារសេដ្ឋកិច្ច ជីវភាពរស់នៅរបស់ខ្លួនឡើងវិញ បន្ទាប់ពីសង្គ្រាមបំផ្លិចបំផ្លាញច្រើនទសវត្សនោះ ពិសេសក្រោយពីប្រទេសជាតិបានរួបរួមកំលាំង និងទឹកដីខ្លួនយ៉ាងពេញលេញដោយសារនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជារួចមក គ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅបន្តជាឧបសគ្គដល់ការអភិវឌ្ឍន៍ និងការរស់នៅជាប្រក្រតីឡើងវិញ ។

ប្រវត្តិនៃការបោសសំអាតមីន ដើម្បីរំដោះទឹកដីសំរាប់បង្កបង្កើនផលបានចាប់ផ្ដើមតាំងពីពេលប្រទេសជាតិត្រូវបានរំដោះផុតពីរបប



ប្រល័យពូជសាសន៍ ប៉ុល ពត នាឆ្នាំ ១៩៧៩ មកម៉្លេះ ដែលមានវីរនារីគង់ សារឿន ដឹកនាំកងអនុសេនាធំដោះមីននៅប៉ែកខាងកើតប្រទេសជាគំរូដ៏ថ្លៃថ្លាបំផុត ។ យ៉ាងណាមិញ ការដោះមីនជាលក្ខណៈមនុស្សធម៌បានចាប់ផ្ដើមពិតប្រាកដនៅឆ្នាំ ១៩៩២ ដើម្បីផ្ដល់ដីសុវត្ថិភាពជូនជនភៀសខ្លួនជាង ៣៥ ម៉ឺន នាក់ ដែលត្រូវធ្វើមាតុភូមិនិវត្តន៍ក្រោមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។

ក៏ប៉ុន្តែជាមួយនឹងតំណាក់កាលនានានៃសន្តិភាវូបនីយកម្ម នៃប្រទេស ការបើកតំបន់នានាដែលពីមុនស្ថិតក្រោមការត្រួតត្រានៃភាគីច្បាំងគ្នាជាមួយនឹងការបើកកាលានុវត្តភាពថ្មីសំរាប់ការធ្វើដំណើរទៅមកនិងការពង្រីកផ្ទៃដីដាំដុះ បញ្ហាមីនបានក្លាយទៅជាបញ្ហាដ៏លំបាកស្មុគស្មាញមួយ និងជាអាទិភាពដ៏ធំមួយក្នុងកិច្ចអភិវឌ្ឍន៍របស់ប្រទេសជាតិ ។ ព្រមជាមួយនេះការកើនឡើងនៃប្រតិបត្តិករ និងសកម្មភាពដោះមីន ភាពចាំបាច់ក្នុងការផ្សព្វផ្សាយអប់រំប្រជាជនក្នុងសហគមន៍ ដែលរស់នៅក្នុងតំបន់មានមីន និងការជួយជនរងគ្រោះដោយសារមីនបានតម្រូវឱ្យរាជរដ្ឋាភិបាលបង្កើតឡើងនូវស្ថាប័នជាតិមួយ សំរាប់ធ្វើនិយ័តកម្មការរៀបចំគោលនយោបាយ ការសំរបសំរួលនិងការត្រួតពិនិត្យសកម្មភាពមីនទាំងមូល គឺអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីនដែលមានរូបខ្ញុំផ្ទាល់ជាប្រធាន ។ គឺក្នុងស្មារតីនេះដែរ ដែលរាជរដ្ឋាភិបាលកម្ពុជាបានសំរេចបង្កើតនូវគោលដៅប្រចាំ

សហសវត្សទី ៩ របស់កម្ពុជា ដើម្បីបំពេញបន្ថែមឱ្យគោលដៅទាំង ៨ របស់អង្គការសហប្រជាជាតិដោយលុបបំបាត់ឱ្យអស់នូវការគំរាមកំហែងទាំងឡាយដោយសារគ្រាប់មីន ។ កាលពីឆ្នាំទៅមិញ រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុម័តនូវឯកសារផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១០-២០១៩ ដើម្បីដឹកនាំវិស័យសកម្មភាពមីនទាំងមូល ដែលមានសង្គតិភាពជាមួយយុទ្ធសាស្ត្រ និងនយោបាយជាតិ ហើយដែលបង្ហាញឱ្យឃើញពីភាពជាម្ចាស់របស់កម្ពុជាក្នុងវិស័យដ៏សំខាន់នេះ ។

ការរៀបចំឡើងវិញ នូវរចនាសម្ព័ន្ធក្នុងវិស័យសកម្មភាពមីន ការបង្កើនសកម្មភាពនានា ដែលគាំទ្រដល់វិស័យនេះ ពិសេសការបង្កើនសកម្មភាពបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ កាកសំណល់ពីសង្គ្រាម ដោយមានការបន្តជួយគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានានោះ បានធ្វើឱ្យចំនួនជនរងគ្រោះដោយសារមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះថយចុះជាបន្តបន្ទាប់គួរឱ្យកត់សំគាល់ គឺពី ៤.៣២០ នាក់ ក្នុងឆ្នាំ ១៩៩៦ មកប្រមាណ ៨០០ នាក់ ជាមធ្យមក្នុងចន្លោះឆ្នាំ ២០០០-២០០៤ ហើយមកត្រឹមក្រោម ៣០០ នាក់ ក្នុងឆ្នាំ ២០០៨ ២០០៩ និង ២០១០ កន្លងទៅ ។ តាមតួលេខ ១០ ខែដើមឆ្នាំនេះចំនួនជនរងគ្រោះដោយសារមីនបានធ្លាក់ចុះមកត្រឹម ១៥២ នាក់ ។ ក្នុងករណីអាចរក្សាបាននូវនិន្នាការនេះសំរាប់រយៈពេល ២ ខែចុងឆ្នាំនេះ



ចំនួនជនរងគ្រោះនឹងធ្លាក់ចុះក្រោម ២០០នាក់ ក្នុងមួយឆ្នាំ ជាលើកដំបូងបង្អស់ក្រោយប្រទេសជាតិត្រូវបានឯកភាព ។

ដំណើរឆ្លងកាត់ ពុះពារជំនះការលំបាកពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសមិទ្ធផលដ៏ធំសន្ធឹកសន្ធាប់ដែលកម្ពុជាបានសំរេចកន្លងទៅនេះ បានផ្តល់ជាមេរៀន បទពិសោធន៏ដ៏មានតំលៃ ដែលយើងនឹងរីករាយចែករំលែកជាមួយអ្នកចូលរួមទាំងអស់ក្នុងកិច្ចប្រជុំលើកទី១១ នេះ ។

*- ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់*

តាំងពីដើមមក កម្ពុជាតែងឈានមុខជានិច្ចក្នុងយុទ្ធនាការប្រឆាំងការប្រើប្រាស់មីន ដែលពេលនោះជនរងគ្រោះកម្ពុជាដូចកញ្ញា **សុង កុសល** និងលោក **ទុន ចាន់ណារ៉េត** គឺជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការបញ្ចុះ-បញ្ចូលអ្នកដឹកនាំនៃប្រទេសជាច្រើនឱ្យចូលរួមជារដ្ឋភាគីនៃអនុសញ្ញា ។

ព្រះមហាវីរក្សត្រ នរោត្តម សីហនុ អតីតព្រះមហាក្សត្រ និងព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក៏តែងប្រទានព្រះទ័យគាំទ្រយ៉ាងពេញទំហឹងដល់ចលនា និងសកម្មភាពប្រឆាំងគ្រាប់មីនផងដែរ ។

ខ្ញុំក៏នៅចាំបានដែរថា នាឆ្នាំ ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើញត្តិគាំទ្រចលនាប្រឆាំងការប្រើប្រាស់មីននេះផងដែរ ។

ការបញ្ជូនកងកំលាំងដោះមីនរបស់កម្ពុជាទៅប្រទេសស៊ូដង់ និងប្រទេសលីបង់ ក្នុងក្របខណ្ឌនៃបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិក៏បង្ហាញពីការរួមចំណែករបស់កម្ពុជា ក្នុងការជួយកាត់បន្ថយគ្រោះថ្នាក់ដោយសារមីនសំរាប់ប្រជាជនដទៃទៀត ក៏ដូចជាការបង្ហាញពីឆន្ទៈ និងការប្តេជ្ញារបស់កម្ពុជាក្នុងការប្រឆាំងនឹងការប្រើប្រាស់គ្រាប់មីនទោះជានៅទីណា និងដើម្បីអ្វីក៏ដោយ ។

*- ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់*

ថ្ងៃនេះអនុសញ្ញាបានវិលត្រឡប់មកទីកន្លែង ដែលអ្វីៗសំរាប់ការប្រឆាំងគ្រាប់មីនបានចាប់ផ្តើមកាលពី ២០ ឆ្នាំមុន ។

នេះជាឱកាសដ៏សំខាន់ ដើម្បីយើងរួមគ្នាពិនិត្យឡើងវិញនូវផ្លូវដែលយើងបានដើរ សមិទ្ធផលដែលយើងបានសំរេច និងការប្រឈមដែលនៅមានបន្តចំពោះមុខយើង ដើម្បីសំរេចគោលដៅនៃអនុសញ្ញា ។

វាក៏ជាឱកាសដើម្បីរំលឹកឡើងវិញថា ទោះបីផ្ទៃដីរាប់រយលានម៉ែត្រក្រឡាត្រូវបានរំដោះ គ្រាប់មីនរាប់សិបលានគ្រាប់ត្រូវបានកំទេច ចំនួនគ្រោះថ្នាក់ត្រូវបានកាត់បន្ថយច្រើនយ៉ាងណាក៏ដោយ ក៏មីននៅតែជាបញ្ហាសំរាប់យើងដោះស្រាយ ហើយគ្មានថ្ងៃដែលយើងអាចឈប់សំរាកបានល្ហឹកណាកិច្ចការនេះមិនទាន់ត្រូវបានបញ្ចប់ ។

វត្តមានរបស់លោកជំទាវ Helen Clark តំណាងដ៏ខ្ពង់ខ្ពស់របស់អង្គការសហប្រជាជាតិ វត្តមានរបស់ព្រះអង្គម្ចាស់ ឯកឧត្តម



លោកជំទាវ អស់លោក លោកស្រី ដែលតំណាងឱ្យប្រទេសជារដ្ឋភាគី និងរដ្ឋមិនមែនភាគី អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័ននានាដ៏ច្រើនកុះករនៅថ្ងៃនេះ បានបញ្ជាក់ឱ្យឃើញពីឆន្ទៈដ៏មុះមុត និងការប្តេជ្ញាដ៏ខ្លាំងក្លារបស់យើងទាំងអស់គ្នា ដើម្បីបញ្ចប់ជាស្ថាពរនូវទុក្ខ-វេទនា និងការឈឺចាប់ដោយសារគ្រាប់មីន ។

ខ្ញុំសូមប្រើប្រាស់វេទិកាដ៏មហោឡារិកនេះ ដើម្បីថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតដល់ដៃគូអភិវឌ្ឍន៍ អង្គការ ស្ថាប័ននានា ដែលតែងជួយគាំទ្រដោយឥតថមថយដល់កិច្ចប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ ខ្ញុំក៏មិនភ្លេចអរគុណដល់តួអង្គទាំងអស់នៃវិស័យសកម្មភាពមីន មានអ្នកបោសសំអាតមីន អ្នកជួយសង្គ្រោះនិងផ្តល់សេវាថែទាំកាយសម្បទាដល់ជនរងគ្រោះដោយសារមីន អ្នកអប់រំអំពីគ្រោះថ្នាក់ដោយសារមីនជាដើម ដែលបានធ្វើពលិកម្មដើម្បីសំរាលទុក្ខលំបាក និងការឈឺចាប់ដោយសារមីន ។

ខ្ញុំសូមសំដែងនូវការគោរព និងកោតសរសើរចំពោះធ្លុងសាមគ្គីភាពដ៏រឹងមាំរបស់រដ្ឋភាគីទាំងអស់ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងតួអង្គទាំងអស់ ដែលបាននិងកំពុងរួមកំលាំងឆ្ពោះទៅសំរេចឧត្តមគតិរួមគឺ **ពិភពលោកគ្មានមីន** ។

នៅក្នុងយុគសម័យនៃស្ថានភាពសេដ្ឋកិច្ចជួបការលំបាក និងមានភាពមិនប្រាកដប្រជាបែបនេះ ផ្លូវធ្វើដំណើរទៅមុខសម្រាប់យើងទាំងអស់

គ្នាក្នុងការអនុវត្តន៏ឱ្យបានសម្រេចនូវគ្រប់កាតព្វកិច្ចនៃអនុសញ្ញា ក៏ដូចជាអ្វីដែលយើងទាំងអស់គ្នាបានសន្យាថា នឹងធ្វើជូនប្រទេសជាតិ និងជនរងគ្រោះរបស់យើង ពិតជាមិនមានភាពងាយស្រួលទេ ។ តែទោះជាយ៉ាងណា ដំណើររបស់យើងមិនត្រូវអាក់ខានបានទេ ហើយសមិទ្ធផលដែលយើងសម្រេចបានកន្លងមក មិនអាចសាបសូន្យទៅវិញដោយសារតែកលយុគ្គផ្នែកហិរញ្ញវត្ថុឡើយ ។ សម្រាប់អណត្តិជាប្រធានរបស់កម្ពុជា យើងនឹងបន្តអនុវត្តនូវអណត្តិក៏ដូចជាអាទិភាព ដែលប្រធានមុនៗបានដាក់ចេញ ជាពិសេសក្នុងផ្នែកជួយឧបត្ថម្ភដល់ជនរងគ្រោះឱ្យបានខ្លាំងក្លាទន្ទឹមនឹងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការជួយគ្នា-ទៅវិញទៅមក ព្រោះយើងខ្ញុំមានជំនឿជឿជាក់ថា កិច្ចសហប្រតិបត្តិការរវាងគ្នា រវាងរដ្ឋនិងរដ្ឋ និងជាមួយដៃគូពាក់ព័ន្ធសំខាន់ៗ គឺជាគំរូនៃកិច្ចសហប្រតិបត្តិការល្អបំផុតឈរលើស្ថានភាព និងកាលៈទេសៈ ដែលយើងទាំងអស់គ្នានឹងជួបប្រទះនៅពេលខាងមុខនេះ ។ ប្រសិនបើយើងមិននាំគ្នាបង្កើនល្បឿន និងប្រសិទ្ធភាពនៃទំលាប់នៃការដោះស្រាយបញ្ហាដែលយើងបានប្រកាន់យកកន្លងមកនោះទេ យើងនឹងមិនងាយទៅដល់គោលដៅចុងក្រោយបង្អស់របស់យើង ដែលចង់បាននូវពិភពលោកមួយដែលគ្មានគ្រាប់មីនបានទេ។ ខ្ញុំសង្ឃឹមថា មិត្តភក្តិរបស់យើងផ្សេងទៀតដែលនៅពុំទាន់បានចូលជាសមាជិក នៃអនុសញ្ញានឹងបន្តរួបរួមជាមួយ-យើងទាំងអស់គ្នាដើម្បីសម្រេចនូវគោលដៅនេះ។



ខ្ញុំសូមជូនពរ សូមឱ្យកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីអនុសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់ ការផលិត ការរក្សាទុក ការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញវាប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា និងជោគជ័យល្អប្រសើរ ។

សូមឱ្យការស្នាក់នៅកម្ពុជា របស់ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវអស់លោក លោកស្រីទាំងអស់ បានប្រកបដោយសុវត្ថិភាព សប្បាយរីករាយជាមួយប្រជាពលរដ្ឋកម្ពុជាយើងខ្ញុំ ។

សូមអរគុណ